ព្រះរាជក្រម

នស/រកម/០១៩៦/២៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * * * * * * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រមលេខ០២ នស_៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស_រកត_១០៩៤_៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ១៩៩៣
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង រប់ស់ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការផ្តល់សច្ចាប័ន លើកិច្ចព្រមព្រៀង ស្តីពី កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេសចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៦ ដែលរដ្ឋសភាបានអនុម័តនាសម័យប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីដូចតទៅ ៖

# ច្បាប់

# ស្តីពី

# ការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការ
# សេដ្ឋកិច្ចនិងបច្ចេកទេស
# ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៤
# រវាង
# ព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាមានិតចិន

ច្បាប់

ស្ដីពី

**ការផ្ដល់សច្ចាប័នលើកិច្ចព្រមព្រៀងស្ដីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេស**

ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៤

រវាង

**ព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាមានិតចិន**

មាត្រា ១.-

ផ្ដល់សច្ចាប័នលើកិច្ចព្រមព្រៀងស្ដីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេសដែលរាជរដ្ឋាភិបាលកម្ពុជាទទួលពីរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិននូវទឹកប្រាក់ចំនួនប្រាំបីលានប្រាំមួយសែនដុល្លារអាមេរិក ( ៨.៦០០.០០០ USD ) ដើម្បីជួសជុលសមិទ្ធិផលនានាដែលបានកសាងឡើងដោយជំនួយចិននិងទូទាត់ការនាំចូលទំនិញមួយចំនួន ។

មាត្រា ២.-

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ មករា ឆ្នាំ១៩៩៦

**នរោត្តម សីហនុ**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្ដលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

បានបង្គំទូលថ្វាយនិងជំរាបជូន
សម្ដេចនាយករដ្ឋមន្ត្រីទី១និងទី២
ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទីតាំង
សហប្រតិបត្តិការ... 

**គាត ឈន់**